# របកគំហើញ៖ ការថយចុះប្រាក់ចំណូល ការកើនឡើងនៃការចំណាយលើការរស់នៅ និងកំណើនបំណុល នៅក្រោយវិបត្តិកូវីដ-១៩



# មាតិកា


ភស្តុតាងបង្ហាញពីទុក្ខលំបាករបស់កម្មករ ៖ ការថយចុះប្រាក់ចំណូល ការកើនឡើងនៃការចំណាយលើការរស់នៅ និងកំណើនបំណុល នៅក្រោយវិបត្តិកូវីដ-១៩

**០១ ការបង្ហាញហេតុផលសម្រាប់ការដំឡើងប្រាក់ឈ្នួលរបស់កម្មករក្នុងវិស័យកាត់ដេរនៅកម្ពុជា** (CNV, 2023) ---------------------- ៥

ចំណូលថយចុះ ---------------------------------------------------------- ៧

ចំណាយកើនឡើង -------------------------------------------------------- ៧

ការជំពាក់បំណុលជាប្រព័ន្ធ (structural indebtedness) ------------------ ៨

**០២ សម្ព័ន្ធប្រាក់ឈ្នួលសមរម្យអាស៊ី** (AFWA, 2022) ÷ **ការសិក្សាអង្កេតប្រាក់ឈ្នួលសមរម្យសម្រាប់កម្ពុជា** -------------------------------- ១០

ចំណូលទាបជាងប្រាក់ឈ្នួលសមរម្យ ------------------------------------- ១០

ការកាត់បន្ថយចំណាយថ្លៃម្ហូបអាហារ ------------------------------------- ១១

**០៣ ការសិក្សាអង្កេតតាមពេលចក្រដោយសហជីពឯករាជ្យ** (CENTRAL, 2023) -------------------------------------------------- ១៣

ការថយចុះចំណូលពីការងារថែមម៉ោង ------------------------------------ ១៣

មិនមានលទ្ធភាពសងបំណុល ------------------------------------------ ១៤

**០៤ សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ----------------------------------- ១៧

និទ្ទាការទី ១ ---------------------------------------------------------- ១៧

និទ្ទាការទី ២ ---------------------------------------------------------- ១៨

និទ្ទាការទី ៣ ---------------------------------------------------------- ១៨

**ឯកសារយោង** ------------------------------------------------------- ២០

# អត្ថបទបង្ហាញពីទុក្ខលំបាករបស់កម្មករ ៖ ការថយចុះប្រាក់ចំណូល ការកើនឡើងនៃការចំណាយលើការរស់នៅ និងកំណើនបំណុល នៅក្រោយវិបត្តិកូវីដ-១៩

ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០២៣

ក្នុងគ្រាដែលសេដ្ឋកិច្ចកម្ពុជាបាន និងកំពុងស្តារឡើងវិញពីវិបត្តិកូវីដ-១៩ វិបត្តិនេះនៅតែបង្កផលប៉ះពាល់លើជីវភាពរស់នៅរបស់កម្មកររោងចក្រកាត់ដេរកម្ពុជា។ ថ្មីៗនេះ ការសិក្សាអង្កេតជាច្រើនជាមួយកម្មករ បានបង្ហាញថា កម្មករភាគច្រើនលើសលប់ជំពាក់បំណុលយ៉ាងច្រើនក្នុងអំឡុងពេលបិទខ្ទប់ដោយសារវិបត្តិកូវីដ-១៩ ក្នុងនោះ កម្មករជាច្រើនមិនមានលទ្ធភាពសងបំណុលនោះទេ។ ក្រៅពីនេះ លទ្ធផលរកឃើញបង្ហាញថា ចំណូលជាក់ស្តែងរបស់កម្មករជាច្រើន មានការថយចុះ ខណៈដែលចំណាយក្នុងការរស់នៅ កើនឡើងដោយសារអតិផរណា។ ឯកសារនេះប្រៀបធៀបលទ្ធផលរកឃើញសំខាន់ៗពីការសិក្សាអង្កេត ដែលធ្វើឡើងដោយ CNV សម្ព័ន្ធប្រាក់ឈ្នួលសមរម្យអាស៊ី (AFWA) និងសហជីពឯករាជ្យកម្ពុជា គឺ សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (CCAWDU) និងសម្ព័ន្ធសហជីពកម្ពុជា (CATU) ក្នុងឆ្នាំ ២០២២ និងឆ្នាំ ២០២៣។ ការសិក្សានីមួយៗ បានរំលេចទិដ្ឋភាពផ្សេងៗនៃភាពត្រដាបត្រដួសផ្នែកសេដ្ឋកិច្ចរបស់កម្មកររោងចក្រកាត់ដេរកម្ពុជា។ ឯកសារនេះមានគោលបំណងសង្ខេប និងសំយោគលទ្ធផលរកឃើញទាំងនេះ ដើម្បីផ្តល់ទិដ្ឋភាពរួមដែលបញ្ជាក់ពីភាពចាំបាច់នៃការដំឡើងប្រាក់ឈ្នួលយ៉ាងច្រើន នៅក្នុងឧស្សាហកម្មកាត់ដេរកម្ពុជា ឱ្យបានមុនការចរចាប្រាក់ឈ្នួលអប្បបរមាថ្នាក់ជាតិ ឆ្នាំ ២០២៣។



៤ កម្មករកម្មការីសម្រាកញ៉ាំអាហារថ្ងៃត្រង់

# ការបង្ហាញហេតុផលសម្រាប់ការដំឡើងប្រាក់ឈ្នួលរបស់កម្មករ ក្នុងវិស័យកាត់ដេរនៅកម្ពុជា (CNV, 2023)

ការសិក្សាអង្កេតដោយប្រើប្រព័ន្ធឌីជីថលរបស់ CNV Internationaal ជាមួយកម្មកររោងចក្រកាត់ដេរកម្ពុជា ក្នុងឆ្នាំ ២០២៣ បង្ហាញពីភាពចាំបាច់នៃការដំឡើងប្រាក់ឈ្នួលក្នុងវិស័យកាត់ដេរកម្ពុជា។ លទ្ធផលរកឃើញបង្ហាញថា ប្រាក់ខែបើកបានសរុបរបស់កម្មកររោងចក្រកាត់ដេរកម្ពុជា ថយចុះតាំងពីឆ្នាំ ២០២២ ទោះជាមានការដំឡើងប្រាក់ឈ្នួលអប្បបរមាកំណត់ដោយច្បាប់ ពី ១៩៤ ដុល្លារ ដល់ ២០០ ដុល្លារ ក្នុងឆ្នាំ ២០២៣ ក៏ដោយ។ ក្រៅពីនេះ ចំណាយសំខាន់ៗបានកើនឡើងយ៉ាងខ្លាំង ដោយសារអតិផរណាតម្លៃ។ ទន្ទឹមនឹងនេះ កម្មករភាគច្រើនលើសលប់នៅតែត្រដាបត្រដួសក្នុងការបង់ការប្រាក់ (មិនគិតសេវា) នៃបំណុលយ៉ាងច្រើន ដែលបន្តកើនឡើងក្នុងអំឡុងវិបត្តិកូវីដ-១៩ ជាពេលដែលមានការបាត់បង់ការងារជាច្រើន ការថយម៉ោងធ្វើការ និងអសន្តិសុខការងារ ដោយសារវិធានការគ្រាអាសន្ន ការលុបចោលការបញ្ជាទិញ និងការស្រុតចុះសេដ្ឋកិច្ចសកល។ ទោះបីជាសេដ្ឋកិច្ចបានងើបឡើងវិញក្រោយវិបត្តិកូវីដ-១៩ ក៏ដោយ ប៉ុន្តែរបាយការណ៍ពីការសិក្សាអង្កេតនេះបង្ហាញថា កម្មកររោងចក្រកាត់ដេរកម្ពុជានៅតែមានជីវភាពត្រដាបត្រដួស ដោយសារតែប្រាក់ឈ្នួលពិតរបស់ពួកគេ ថយចុះ ហើយកម្មករជាច្រើនត្រូវជាប់ផុងក្នុងអន្ទាក់បំណុល និងការបង់ការប្រាក់។

សម្រាប់របាយការណ៍នេះ CNV បានសិក្សាអង្កេតកម្មកររោងចក្រកាត់ដេរកម្ពុជាចំនួន ១.១៩៧ នាក់ ដោយប្រើកម្មវិធីសិក្សាអង្កេតតាមប្រព័ន្ធឌីជីថល នៅអំឡុងខែ មេសា-ឧសភា ឆ្នាំ ២០២៣។ ការសិក្សាអង្កេតបានសួរសំណួរពាក់ព័ន្ធនឹងចំណូលដែលរកបាន ចំណាយក្នុងការរស់នៅ បំណុល និងស្ថានភាពការងារ។ ក្នុងចំណោមកម្មការនីដែលមានចំនួន ៧៨% នៃចម្លើយសរុប អ្នកឆ្លើយតប ៩០% ជាសមាជិកសហជីព និង ៩៤% ជាកម្មករផ្នែកផលិត។ ទោះបីជាសំណាកនេះមិនតំណាងឱ្យស្ថិតិកម្មកររោងចក្រកាត់ដេរកម្ពុជាជារួម ហើយសំណាកនេះខុសពីសំណាកនៃការសិក្សាអង្កេតឆ្នាំ ២០២២ ក៏ដោយ ប៉ុន្តែគេអាចចាត់ទុកលទ្ធផលដែលទទួលបាន ជាសូចនាករបង្ហាញពីការវិវត្តមួយភាគធំនៃជីវភាពរស់នៅរបស់កម្មករក្នុងឆ្នាំ ២០២៣។



៦ កម្មការីទិញលៀសហាលសម្រាប់ញាំបាយថ្ងៃត្រង់

## ចំណូលថយចុះ

ក្នុងចំណោមកម្មករដែលត្រូវបានសិក្សាអង្កេត មានភាពខុសគ្នាតិចតួចក្នុងការរាយការណ៍ពីប្រាក់ឈ្នួល ដោយកម្មករ ៩៧% លើកឡើងថា ពួកគេមានប្រាក់ខែគោល ២០០-២២៥ ដុល្លារ។ ប្រាក់ខែគោលដែលបានរាយការណ៍ គឺជាមធ្យម ២០០ ដុល្លារ។ មានន័យថា ចំណូលរបស់កម្មករភាគច្រើនលើសលប់ គ្មានអ្វីក្រៅពីប្រាក់ខែគោលចំនួន ២០០ ដុល្លារនោះទេ។ ប្រធានត្រួតពិនិត្យដែលភាគច្រើនជាមុខតំណែងរបស់បុរស ច្រើនតែទទួលបានប្រាក់ខែខ្ពស់ ខណៈដែលកម្មករធម្មតា ដែលភាគច្រើនជាស្ត្រី ទទួលបានត្រឹមប្រាក់ឈ្នួលអប្បបរមាប៉ុណ្ណោះ។ ក្រៅពីប្រាក់ឈ្នួលគោល កម្មករទទួលបានសាហ៊ុយធ្វើដំណើរ ៧ ដុល្លារ និងប្រាក់បន្ថែម ១០ ដុល្លារក្នុងមួយខែសម្រាប់វត្តមាន ១០០% (កម្មករ ៧១% លើកឡើងថា ពួកគេបានទទួលប្រាក់ឧបត្ថម្ភនេះ) ក៏ដូចជាអត្ថប្រយោជន៍អតីតភាពការងារ ទៅតាមរយៈពេលធ្វើការ និងប្រាក់បន្ថែមលើជំនាញ សម្រាប់ការងារមួយចំនួន។ កម្មករ ៨០% លើកឡើងថា ពួកគេធ្វើការថែមម៉ោង ដោយទទួលបានប្រាក់ថែមម៉ោងជាមធ្យម ២០ ដុល្លារក្នុងមួយខែ បូករួមនឹងប្រាក់ឧបត្ថម្ភថ្លៃបាយ 0,៥ ដុល្លារក្នុងមួយថ្ងៃសម្រាប់ការងារថែមម៉ោង ដែលជាមធ្យមគឺស្មើនឹង ១០ ដុល្លារក្នុងមួយខែ។ ដូច្នេះ ប្រាក់ឈ្នួលគោល បូករួមនឹងអត្ថប្រយោជន៍ជាកាតព្វកិច្ច និងប្រាក់បន្ថែម ស្មើនឹងប្រាក់ខែសរុបជាមធ្យមចំនួន ២៥៧ ដុល្លារ។ ចំនួននេះបង្ហាញពីការថយចុះយ៉ាងខ្លាំងពីចំណូលជាមធ្យម ២៧១ ដុល្លារក្នុងមួយខែ ដែលកម្មករបានលើកឡើងក្នុងការសិក្សាអង្កេតរបស់ CNV ក្នុងឆ្នាំ ២០២២ ទោះបីជាមានការដំឡើងប្រាក់ឈ្នួលអប្បបរមា ៦ ដុល្លារ ក្នុងឆ្នាំ ២០២៣ ក៏ដោយ។ មានន័យថា ការផ្តល់ប្រាក់បន្ថែមសម្រាប់ការងារថែមម៉ោង និងអត្ថប្រយោជន៍ផ្សេងទៀត ថយចុះច្រើន។

## ចំណាយកើនឡើង

ប្រាក់ខែជាក់ស្តែងជាមធ្យម ២៥៧ ដុល្លារ គឺទាបជាងប្រាក់ឈ្នួលបន្ទាត់ភាពក្រីក្រ LMICs របស់ធនាគារពិភពលោកសម្រាប់កម្ពុជា ដែលបានកំណត់ដល់ ២៦៣ ដុល្លារសម្រាប់ឆ្នាំ ២០២៣។ ជាក់ស្តែង មធ្យមភាគចំណូលដែលបានលើកឡើង គឺទាបខ្លាំងជាងមធ្យមភាគចំណាយប្រចាំខែចំនួន ៤២៥ ដុល្លារ ដែលត្រូវបានលើកឡើងក្នុងការសិក្សាអង្កេតរបស់ CNV។ សម្រាប់ចំណាយប្រចាំខែ ជាមធ្យមគឺ ៤២% ជាចំណាយថ្លៃម្ហូបអាហារ, ៥២% ជាចំណាយមិនពាក់ព័ន្ធនឹងម្ហូបអាហារ និង ៦% ជាប្រាក់ផ្ញើទៅផ្ទះ។ ខណៈដែលកម្មករ ៧១% លើកឡើងថា ពួកគេមានសមាជិកគ្រួសារម្នាក់ទៀតជួយរកចំណូល ដែលមានចំណូលជាមធ្យម ២៥០ ដុល្លារក្នុងមួយខែ កម្មករ ៦៣% លើកឡើងពីការមិនពេញចិត្ត (ជាខ្លាំង) ចំពោះកម្រិតចំណូលបច្ចុប្បន្នរបស់ពួកគេ។ ក្រៅពីនេះ កម្មករ ៧០% លើកឡើងថា ពួកគេមិនអាចសន្សំប្រាក់ទុកសម្រាប់គ្រាអាសន្នបានឡើយ ខណៈដែលកម្មករ ៤០% លើកឡើងពីការធ្វើការងារមួយទៀតដើម្បីបង្គ្រប់ការចាយវាយ។ ចំណាយប្រចាំខែជាមធ្យម ៤២៥ ដុល្លារ ដែលកម្មករបានលើកឡើង ជាការកើនឡើងយ៉ាងច្រើនពីចំណាយប្រចាំខែជាមធ្យម ៣៤៥ ដុល្លារ ដែលកម្មករបាន

លើកឡើងក្នុងការសិក្សាអង្កេតរបស់ CNV ក្នុងឆ្នាំ ២០២២។ មានន័យថា ចំណាយក្នុងការរស់នៅរបស់កម្មកររោងចក្រកាត់ដេរកម្ពុជា កើនឡើងយ៉ាងខ្លាំង ដែលបង្ហាញពីការកើនឡើងនៃតម្លៃទំនិញចាំបាច់ ខ្ពស់ជាងអត្រាអតិផរណាផ្លូវការ ៥,៣% ដែលត្រូវបានរាយការណ៍សម្រាប់ប្រទេសកម្ពុជាក្នុងឆ្នាំ ២០២៣។

## ការជំពាក់បំណុលជាប្រព័ន្ធ (structural indebtedness)

ដោយសារភាពត្រដាបត្រដួសជាប្រព័ន្ធ ក៏ដូចជាផលប៉ះពាល់ជាបន្តបន្ទាប់នៃវិបត្តិកូវីដ-១៩ កម្មករ ៧៧% លើកឡើងថា ពួកគេជំពាក់បំណុល។ មធ្យមភាគបំណុលដែលកម្មករបានលើកឡើង គឺរហូតដល់ ៥.០០០ ដុល្លារ ដែលស្មើនឹងប្រាក់ឈ្នួលជិត ២ ឆ្នាំ។ ជាមួយនឹងការលើកឡើងពីការខ្ចីប្រាក់ក្រោមអត្រាការប្រាក់ខ្ពស់ កម្រិតបំណុលនេះអាចតម្រូវឱ្យមានការបង់ការប្រាក់ចាប់ពី ១០០ ដុល្លារដល់ ២៥០ ដុល្លារក្នុងមួយខែ។ មានន័យថា កម្មករភាគច្រើនចាយវាយប្រាក់ឈ្នួលមួយភាគធំលើការបង់ការប្រាក់បំណុលរបស់ពួកគេ។ ក្នុងចំណោមកម្មករដែលជំពាក់បំណុល កម្មករ ១១% លើកឡើងថាពួកគេបានខ្ចីប្រាក់ដើម្បីទូទាត់សងកម្ចីមួយផ្សេងទៀត។ មូលហេតុផ្សេងទៀតនៃការខ្ចីប្រាក់គេ រួមមានកែលម្អផ្ទះ ទិញម៉ូតូ បង់ថ្លៃពេទ្យ និងទិញម្ហូបអាហារ។ ក្នុងចំណោមកម្មករទាំងអស់ដែលជំពាក់បំណុល កម្មករ ៧០% លើកឡើងថា ពួកគេបានខ្ចីប្រាក់ពីធនាគារ, ២០% បានខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ , ៦% បានខ្ចីប្រាក់ពីអ្នកចងការប្រាក់ និង ៤% បានខ្ចីប្រាក់ពីមិត្តភក្តិ និងគ្រួសារ។

លទ្ធផលរកឃើញពីការសិក្សាអង្កេតរបស់ CNV បង្ហាញពីស្ថានភាពដុនដាបរបស់កម្មកររោងចក្រកាត់ដេរកម្ពុជា ក្នុងពេលដែលចំណូលនៅដដែល ឬថយចុះ ខណៈដែលចំណាយក្នុងការរស់នៅកើនឡើងខ្លាំង។ លទ្ធផលទាំងនោះក៏មានន័យថា កម្មករមិនអាចរួចផុតពីអម្រែកបំណុលយ៉ាងធ្ងន់នេះផងដែរ។ យោងតាមការសិក្សាអង្កេត កម្មករ ៦៣% លើកឡើងថា ពួកគេត្រូវការចំណូលយ៉ាងហោចណាស់ ៣០០-៥០០ ដុល្លារក្នុងមួយខែដើម្បីរ៉ាប់រងចំណាយសំខាន់ៗ ដែលស្មើនឹងការដំឡើងប្រាក់ឈ្នួលគោល ៥០%-១៥០%។ ក្នុងករណីណាក៏ដោយ ចាំបាច់ត្រូវមានការដំឡើងប្រាក់ឈ្នួលយ៉ាងច្រើនដើម្បីស្រោចស្រង់ស្ថានភាពត្រដាបត្រដួសនេះ និងអាចឱ្យកម្មកររួចផុតពីអន្ទាក់បំណុល។ ដូច្នេះរបាយការណ៍របស់ CNV អំពាវនាវឱ្យនិយោជក ក្រុមហ៊ុនម៉ាកយីហោសំលៀកបំពាក់ និងរាជរដ្ឋាភិបាលកម្ពុជា ធ្វើយ៉ាងណាដំឡើងប្រាក់ឈ្នួលឱ្យបានច្រើន។



៩ កម្មករកម្មការនីឡើងរថយន្តដឹកកម្មករទៅធ្វើការតាំងពីវេលាព្រឹកព្រលឹមម៉ោង ៥

## សម្ព័ន្ធប្រាក់ឈ្នួលសមរម្យអាស៊ី (AFWA, 2022) ÷ ការសិក្សាអង្កេតប្រាក់ឈ្នួលសមរម្យសម្រាប់កម្ពុជា

ក្នុងការស្វែងយល់ពីផលប៉ះពាល់នៃការស្រុតចុះសេដ្ឋកិច្ចលើជីវភាពរស់នៅរបស់កម្មកររោងចក្រកាត់ដេរ សម្ព័ន្ធប្រាក់ឈ្នួលអាស៊ី (AFWA) បានធ្វើការសិក្សាអង្កេតក្នុងឆ្នាំ ២០២២ ដើម្បីសិក្សាពីចំណាយថ្លៃម្ហូបអាហារ និងអាហារូបត្ថម្ភរបស់កម្មកររោងចក្រកាត់ដេរកម្ពុជា។ ក្រៅពីនេះ មានការប្រៀបធៀបឆ្លងប្រទេស លើស្ថានភាពតាមបណ្តាប្រទេសផលិតសំលៀកបំពាក់នៅអាស៊ីទក្សិណ និងអាស៊ីអាគ្នេយ៍ ដើម្បីកំណត់កម្រិតប្រាក់ឈ្នួលសមរម្យសម្រាប់ប្រទេសនីមួយៗ។ លទ្ធផលរកឃើញពីការសិក្សាអង្កេតដែលធ្វើឡើងដោយ AFWA នៅកម្ពុជា កាលពីឆ្នាំ ២០២២ បង្ហាញថា កម្មកររោងចក្រកាត់ដេរកម្ពុជា បន្ថយចំណាយថ្លៃម្ហូបអាហារ ក៏ដូចជាចំណាយមិនពាក់ព័ន្ធនឹងម្ហូបអាហារ ដោយសារចំណូលមិនគ្រប់គ្រាន់។ ចំណុចនេះបានបង្កឱ្យមានការព្រួយបារម្ភពីបញ្ហាកង្វះអាហារូបត្ថម្ភក្នុងចំណោមកម្មកររោងចក្រកាត់ដេរកម្ពុជា។ របាយការណ៍នេះលម្អិតពីលទ្ធផលរកឃើញពីការសិក្សាអង្កេតចំណាយលើសម្ភារៈប្រើប្រាស់ក្នុងគ្រួសារ ដែលបានធ្វើឡើងក្នុងប្រទេសកម្ពុជាកាលពីអំឡុងខែ មករា-មីនា ឆ្នាំ ២០២២។ ការសិក្សាអង្កេតនេះលម្អិតពីចំណាយថ្លៃម្ហូបអាហារ និងចំណាយមិនពាក់ព័ន្ធនឹងម្ហូបអាហាររបស់កម្មកររោងចក្រកាត់ដេរកម្ពុជា ២១៣ នាក់។ ក្នុងនោះ កម្មការនីមាន ៨២% មានន័យថា កម្លាំងពលកម្មក្នុងវិស័យនេះផ្អែកខ្លាំងលើយេនឌ័រ។ របាយការណ៍នេះក៏បានកំណត់កម្រិតប្រាក់ឈ្នួលសមរម្យ ទៅតាមតម្រូវការជាក់ស្តែងនៃចំណាយថ្លៃម្ហូបអាហារ និងចំណាយមិនពាក់ព័ន្ធនឹងម្ហូបអាហារសម្រាប់ក្រុមគ្រួសាររបស់កម្មកររោងចក្រកាត់ដេរផងដែរ។

## ចំណូលទាបជាងប្រាក់ឈ្នួលសមរម្យ

កម្មករដែលត្រូវបានសិក្សាអង្កេត លើកឡើងពីចំណូលប្រចាំខែជាមធ្យម ២៥៤ ដុល្លារក្នុងមនុស្សម្នាក់ និង ៣៧៨ ដុល្លារក្នុងមួយគ្រួសារ។ ទោះជាយ៉ាងណា កម្មករ ៤៥% លើកឡើងថា ពួកគេជាអ្នករកចំណូលតែម្នាក់គត់នៅក្នុងគ្រួសារ ហើយកម្មករភាគច្រើនលើកឡើងថា ពួកគេត្រូវផ្គត់ផ្គង់កូន (តូច)។ ក្រៅពីនេះ មានកម្មករត្រឹមតែ ៤៥% ប៉ុណ្ណោះដែលលើកឡើងថា ពួកគេបានទទួលប្រាក់បន្ថែម ដូចជាប្រាក់ឧបត្ថម្ភថ្ងៃបុណ្យ ឬប្រាក់ឧបត្ថម្ភសម្រាប់ការសម្រេចបានគោលដៅផលិតកម្ម។ តាមការរាយការណ៍ បើបូកបញ្ចូលចំណាយប្រចាំខែក្នុងមួយគ្រួសារ លើថ្លៃម្ហូបអាហារ និងចំណាយមិនពាក់ព័ន្ធនឹងម្ហូបអាហារ គឺជាមធ្យម ៤២៤ ដុល្លារ ដែលជាចំណាយខ្ពស់ខ្លាំង ជាងចំណូលគ្រួសារជាមធ្យម។ ដូច្នេះ AFWA បានស្នើឱ្យដំឡើងប្រាក់ឈ្នួលសមរម្យដល់ ២.៣៣៤.៦៧៧ រៀល (៥៦២ ដុល្លារ) ក្នុងមួយខែ ខណៈដែលការប្រៀបធៀបឆ្លងប្រទេសដោយ AFWA ក្នុងឆ្នាំ ២០២២ បានស្នើឱ្យដំឡើងប្រាក់ឈ្នួលសមរម្យរហូតដល់ ៧០១ ដុល្លារ។

## ការកាត់បន្ថយចំណាយថ្លៃម្ហូបអាហារ

ជាមធ្យម កម្មករដែលត្រូវបានសិក្សាអង្កេត លើកឡើងថា ពួកគេចំណាយ ១១.៨១៩ រៀល (ជិត ៣ ដុល្លារ) ក្នុងម្នាក់ លើថ្លៃម្ហូបអាហារ ស្មើនឹងអាហារូបត្ថម្ភ ២.៥២១ គីឡូកាឡូរីក្នុងមួយថ្ងៃ។ ខណៈដែលតួលេខនេះលើសកម្រិតភាពក្រីក្រអន្តរជាតិ (២៤០០ គីឡូកាឡូរី) បន្តិច កម្មករលើកឡើងថា អាហារូបត្ថម្ភជាង ១/៣ ទទួលបានពីបាយ មិនមែនអាហារស្រស់ៗដែលមានតម្លៃថ្លៃនោះទេ។ ចំណុចនេះបានបង្កការព្រួយបារម្ភលើបញ្ហាអាហារូបត្ថម្ភ។ ការប្រៀបធៀបជាអន្តរជាតិបង្ហាញថា ចំណាយថ្លៃម្ហូបអាហារសំខាន់ៗនៅកម្ពុជា គឺច្រើនជាងប្រទេសផលិតសំលៀកបំពាក់ភាគច្រើនផ្សេងទៀតនៅអាស៊ីទក្សិណ និងអាស៊ីអាគ្នេយ៍។ ដូច្នេះ ចំណាយប្រចាំខែជាមធ្យមលើថ្លៃម្ហូបអាហារ ចំនួន ២០៧ ដុល្លារក្នុងមួយគ្រួសារ ស្មើនឹងចំណាយត្រឹមតែ ៦៨% នៃការចំណាយលើម្ហូបនេះ ប្រសិនបើកម្មករទទួលបានប្រាក់ឈ្នួលសមរម្យ។ កម្មករលើកឡើងថា ចំណាយប្រចាំខែជាមធ្យមដែលមិនពាក់ព័ន្ធនឹងម្ហូបអាហារគឺ ២១៧ ដុល្លារ ដែលស្មើនឹងចំណាយដែលត្រូវបានប៉ាន់ស្មាន ត្រឹមតែ ៧៨% ប៉ុណ្ណោះ ប្រសិនបើកកម្មករទទួលបានប្រាក់ឈ្នួលសមរម្យ។

លទ្ធផលរកឃើញពីការសិក្សាអង្កេតនេះបង្ហាញថា កម្មកររោងចក្រកាត់ដេរកម្ពុជាកំពុងកាត់បន្ថយចំណាយថ្លៃម្ហូបអាហារ ដោយសារតែប្រាក់ឈ្នួលរបស់ពួកគេមិនគ្រប់គ្រាន់សម្រាប់ចំណាយសំខាន់ៗក្នុងការរស់នៅ។ ខណៈដែលប្រាក់ឈ្នួលត្រឹមតែគ្រប់អាចឱ្យកម្មករទិញម្ហូបអាហារ លទ្ធផលទាំងនេះក៏បញ្ជាក់ផងដែរថា កម្មករប្រហែលជាមិនអាចលៃលករបបអាហារសុខភាពដែលមានគុណតម្លៃអាហារូបត្ថម្ភបានឡើយ។ ខណៈដែលការប្រៀបធៀបឆ្លងប្រទេសបង្ហាញថា ប្រាក់ឈ្នួលណូមីណាលនៅកម្ពុជា ខ្ពស់ជាងប្រាក់ឈ្នួលណូមីណាលក្នុងប្រទេសផលិតសំលៀកបំពាក់ជាច្រើនផ្សេងទៀតនៅអាស៊ីទក្សិណ និងអាស៊ីអាគ្នេយ៍ ចំណាយថ្លៃម្ហូបអាហារនៅកម្ពុជាក៏ខ្ពស់ខ្លាំង ជាងបណ្តាប្រទេសទាំងនោះដែរ។ ដូច្នេះ គេត្រូវឆ្លុះបញ្ចាំងពីភាពខុសគ្នានៃអំណាចទិញ ក្នុងប្រាក់ឈ្នួលសមរម្យនៅកម្ពុជា ដែល AFWA ប៉ាន់ស្មានថា គួរដំឡើងដល់ ៧០១ ដុល្លារសម្រាប់ឆ្នាំ ២០២៣។ លើសពីនេះ ការណ៍ដែលកម្មកររោងចក្រកាត់ដេរកម្ពុជាភាគច្រើនជាស្ត្រី (ដូចនៅតាមប្រទេសផលិតសំលៀកំពាក់ភាគច្រើនផ្សេងទៀត) មានន័យថា គេត្រូវពិចារណាពីការថែទាំកុមារ និងទម្រង់ផ្សេងទៀតនៃការងារមិនទទួលបានប្រាក់ឈ្នួល និងការចំណាយ ដែលជាទូទៅ ជាការងាររបស់ស្ត្រី នៅពេលកំណត់ប្រាក់ឈ្នួលសមរម្យ។



 កម្មករកម្មការនីចុះពីរថយន្តនៅមុខរោងចក្រ

## ការសិក្សាអង្កេតតាមរោងចក្រដោយសហជីពឯករាជ្យ (CENTRAL, 2023)

ខណៈដែលមានបញ្ហាថយចុះចំណូល ឡើងថ្លៃទំនិញ និងបំណុលកើនឡើង នៅក្នុងឧស្សាហកម្មកាត់ដេរកម្ពុជា ការសិក្សាអង្កេតកម្មករដោយសហជីពឯករាជ្យ CCAWDU និង CATU ដែលបានផ្តល់ព័ត៌មានករណីសិក្សាលម្អិតស្តីពីរោងចក្រកាត់ដេរជាច្រើននៅកម្ពុជា ក៏ដូចជាជីវភាព និងលក្ខខណ្ឌការងាររបស់និយោជិតនៅតាមរោងចក្រទាំងនោះបង្ហាញថា ស្ថានភាពនៅតាមរោងចក្រនីមួយៗគឺខុសគ្នា។ លទ្ធផលនៃការសិក្សាអង្កេតបង្ហាញថា ជាទូទៅ ចំណូលរបស់កម្មករថយចុះចាប់តាំងពីវិបត្តិកូវីដ-១៩ ព្រោះកម្មករជាច្រើនទទួលបានប្រាក់ឈ្នួលទាប និងមិនសូវមានការងារថែមម៉ោង។ លើសពីនេះ គោលដៅផលិតកម្ម ក្នុងទម្រង់ជាប្រាក់ដេរគិតបុង បានក្លាយជាគោលការណ៍ទូទៅ និងជាការដាក់ទណ្ឌកម្មកម្មករ ជាជាងការផ្តល់រង្វាន់ដល់កម្មករដែលសម្រេចបានផលិតភាពខ្ពស់។ ដោយសារបន្ទុកបំណុលកើនឡើងក្នុងវិបត្តិកូវីដ-១៩ ការថយចុះចំណូល និងឡើងថ្លៃទំនិញ មានកម្មករកាន់តែច្រើនឡើងដែលជំពាក់បំណុលកាន់តែច្រើន។ ក្រៅពីនេះ ការសិក្សាអង្កេតបានបង្ហាញថា បញ្ហាទាំងនេះកាន់តែមានភាពជ្រាលជ្រៅនៅក្នុងរោងចក្រមួយចំនួន ជាងនៅក្នុងរោងចក្រផ្សេងទៀត។

ការសិក្សាអង្កេតនេះ ចូលរួមដោយកម្មករកាត់ដេរ ៣០៨ នាក់ (ស្រី ៦៩% និងភាគច្រើនជាសមាជិកសហជីព) និងធ្វើឡើងចាប់ពីខែ ធ្នូ ឆ្នាំ ២០២២ ដល់ខែ មករា ឆ្នាំ ២០២៣។ របាយការណ៍នេះផ្តល់ព័ត៌មានលម្អិតស្តីពីស្ថានភាពផ្សេងៗរបស់រោងចក្រកាត់ដេរចំនួន ៧។ របាយការណ៍នេះប្រៀបធៀបលទ្ធផលពីការសិក្សាអង្កេតចុងក្រោយ ទៅនឹងការសិក្សាអង្កេតមុនវិបត្តិកូវីដ-១៩ ដែលបង្ហាញថា ស្ថានភាពកាន់តែដុនដាប។

### ការថយចុះចំណូលពីការងារថែមម៉ោង

លទ្ធផលនៃការសិក្សាអង្កេតនេះបង្ហាញថា ជាទូទៅ ប្រាក់ខែជាក់ស្តែងរបស់កម្មកររោងចក្រកាត់ដេរកម្ពុជាថយចុះ បើធៀបនឹងកម្រិតមុនវិបត្តិកូវីដ-១៩។ ក្នុងការសិក្សាអង្កេតចុងក្រោយ កម្មករ ៧៥,៥% លើកឡើងថា ពួកគេទទួលបានប្រាក់ឈ្នួលគោល ២០០ ដុល្លារ (ឬតិចជាងនេះ) ធៀបនឹងកម្មករត្រឹមតែ ៥១% ប៉ុណ្ណោះដែលលើកឡើងដូច្នេះ កាលពីមុនវិបត្តិកូវីដ-១៩។ ផ្ទុយទៅវិញ ចំណុចនេះមានន័យថា ទោះបីជាមានការដំឡើងប្រាក់ឈ្នួលអប្បបរមាចំនួន ១០ ដុល្លារនៅចន្លោះឆ្នាំ ២០២០ និងឆ្នាំ ២០២៣ ក៏ដោយ ក៏កម្មករជាច្រើនទទួលបាន

ប្រាក់ឈ្នួលគោលតិចជាងមុន។ កម្មករ ៦៥% លើកឡើង ប្រាក់ឈ្នួលរបស់ពួកគេគឺមិនគ្រប់គ្រាន់សម្រាប់ការចិញ្ចឹមជីវិត។ របាយការណ៍នេះបង្ហាញថា ការប្រែប្រួលនេះមានភាពជ្រាលជ្រៅកាន់តែខ្លាំងនៅក្នុងរោងចក្រមួយចំនួន ជាងនៅក្នុងរោងចក្រផ្សេងទៀត។ លើសពីនេះឱកាសរកចំណូលបន្ថែម តាមរយៈការងារថែមម៉ោង ក៏ថយចុះផងដែរ ដោយកម្មករ ៦៧% រាយការណ៍ថា ពួកគេមិនបានទទួលប្រាក់ថែមម៉ោងទាល់តែសោះ ធៀបនឹងកម្មករត្រឹមតែ ២១% ប៉ុណ្ណោះដែលរាយការណ៍ដូច្នេះ នៅឆ្នាំ ២០២០។ ខណៈដែលកម្មករ ៥៣% ធ្វើការថែមម៉ោងលើស ១០ ម៉ោងក្នុងមួយសប្តាហ៍ នៅមុនឆ្នាំ ២០២០ បច្ចុប្បន្ន មានកម្មករតែ ៤% ប៉ុណ្ណោះដែលធ្វើការថែមម៉ោងដូច្នេះ។ ហេតុនេះ ការទូទាត់ប្រាក់ថែមម៉ោងប្រចាំខែជាមធ្យម ថយពី ៣៤ ដុល្លារ មកត្រឹម ១១ ដុល្លារក្នុងអំឡុងពេលនេះ។ គួរកត់សម្គាល់ថា នេះហាក់ដូចជានិន្នាការទូទៅនៅក្នុងរោងចក្រទាំងអស់ ប៉ុន្តែវាមានភាពជ្រាលជ្រៅនៅក្នុងរោងចក្រមួយចំនួន ជាងនៅក្នុងរោងចក្រផ្សេងទៀត។

តាមសេចក្តីរាយការណ៍ រោងចក្រមួយចំនួនផ្តល់ការងារតិចជាងស្តង់ដារ ដែលបានកំណត់ការងារ ៤៨ ម៉ោង ក្នុងមួយសប្តាហ៍ ដោយសារមិនសូវមានការបញ្ជាទិញ ដែលធ្វើឱ្យមានការកាត់បន្ថយប្រាក់ឈ្នួលគោល តាមរយៈការបង្ខំឱ្យកម្មករដាក់ច្បាប់ឈប់សម្រាកដោយមិនទទួលបានប្រាក់ឈ្នួលនៅថ្ងៃខ្លះ។ មានន័យថា កម្មករក៏នឹងមិនទទួលបានប្រាក់បន្ថែមពេញពីប្រាក់វង្វាន់ធ្វើការទៀងទាត់។ ដូច្នេះ កម្មករជាច្រើនមិនអាចរកចំណូលពីការងារថែមម៉ោង ឬប្រាក់បន្ថែមពីការដេរគិតបុងបានឡើយ ព្រោះមិនមានការងារគ្រប់គ្រាន់។ ខណៈដែលការងារដេរគិតបុង ធ្លាប់តែជាជម្រើសមួយទៀតដែលកម្មករអាចបង្កើនចំណូលតាមរយៈការខិតខំធ្វើការ គោលដៅផលិតកម្មហាក់ត្រូវបានយកមកប្រើប្រាស់កាន់តែច្រើនឡើងដើម្បីដាក់សម្ពាធឱ្យនិយោជិតប្រឹងធ្វើការ ឬដាក់ទណ្ឌកម្មពួកគេ នៅពេលពួកគេមិនសម្រេចគោលដៅផលិតកម្ម ទោះបីជាមិនមានការងារថែមម៉ោងក៏ដោយ។

## មិនមានលទ្ធភាពសងបំណុល

ក្រោមវិបត្តិសេដ្ឋកិច្ចដោយសារជំងឺកូវីដ-១៩ និងស្ថានភាពសេដ្ឋកិច្ចដុនដាបរបស់កម្មកររោងចក្រកាត់ដេរកម្ពុជាបច្ចុប្បន្ន កម្មករស្ទើរតែទាំងអស់បានលើកឡើងថា ពួកគេជំពាក់បំណុល។ អ្នកឆ្លើយតប ៩១% លើកឡើងថា ពួកគេជំពាក់បំណុល។ ក្នុងនោះ អ្នកឆ្លើយតប ៧០% លើកឡើងថា បំណុលរបស់ពួកគេកើនឡើងតាំងពីវិបត្តិកូវីដ-១៩ ដោយសារតែរោងចក្រផ្អាកដំណើរក្នុងអំឡុងពេលបិទខ្ទប់ និងការថយចុះចំណូល និងការកើនឡើងនៃចំណាយក្នុងការរស់

នៅ ចាប់តាំងពីពេលនោះមក។ កម្មករ ៣៧% លើកឡើងថា ពួកគេត្រូវសងផ្តាច់កម្ចីជាច្រើន។ ខណៈដែលកម្មករភាគច្រើនលើកឡើងថា ពួកគេខ្ចីប្រាក់ពីអ្នកផ្តល់កម្ចីផ្លូវការ ដូចជា ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ កម្មករ ២៧% លើកឡើងថា ពួកគេខ្ចីប្រាក់ពីអ្នកចងការប្រាក់ដែលយកការប្រាក់ខ្ពស់ (loan shark) និងកម្មករ ១៨% លើកឡើងថា ពួកគេខ្ចីប្រាក់ពីមិត្តភក្តិ និងគ្រួសារ ជាមួយនឹងអត្រាការប្រាក់ ២០% ក្នុងមួយខែ។ ដូច្នេះ កម្មករ ៥៤% លើកឡើងថា ជារឿយៗ ពួកគេមិនមានលទ្ធភាពសងបំណុលនោះទេ។ ជាញឹកញាប់ ការមិនមានលទ្ធភាពបង់ការប្រាក់ មានន័យថា កម្មករមួយចំនួនត្រូវលក់ទ្រព្យសម្បត្តិ ដូចជា ដីធ្លីដើម្បីដោះទាល់ ឬអាចធ្វើឱ្យពួកគេស្ថិតក្នុងស្ថានភាពពិបាកជាមួយអ្នកផ្តល់កម្ចី។

លទ្ធផលនៃការសិក្សាអង្កេតដែលធ្វើឡើងដោយសហជីពនេះ បង្ហាញថា ប្រាក់ឈ្នួលពិតថយចុះដោយសារអតិផរណា ហើយប្រាក់ឈ្នួលឈ្មួលមីណលមានការថយចុះ សម្រាប់កម្មករជាច្រើន តាំងពីឆ្នាំ ២០២០ មក។ ក្រៅពីការថយចុះប្រាក់ឈ្នួលគោល ប្រាក់ថែមម៉ោង និងប្រាក់ដេរគិតបុងក៏មិនមានដែរ។ បំណុលដែលកើនឡើងក្នុងអំឡុងវិបត្តិកូវីដ-១៩ បន្តដាក់បន្ទុកលើកម្មករភាគច្រើនលើសលប់ ដែលកម្មករភាគច្រើនខំរកលុយបង់ការប្រាក់ (មិនគិតការបង់ប្រាក់ដើម)។ ខណៈដែលនិន្នាការទាំងនេះលេចឡើងនៅក្នុងរោងចក្រទាំងអស់ដែលត្រូវបានសិក្សាអង្កេត វាមានភាពជ្រាលជ្រៅនៅក្នុងរោងចក្រមួយចំនួន ជាងនៅក្នុងរោងចក្រផ្សេងទៀត ព្រោះបញ្ហាទាំងនេះមានភាពជ្រាលជ្រៅបំផុតនៅក្នុងរោងចក្រដែលរងផលប៉ះពាល់យ៉ាងខ្លាំងដោយសារវិបត្តិកូវីដ-១៩។ លទ្ធផលរកឃើញពីការសិក្សាអង្កេតនេះ បញ្ជាក់ពីភាពចាំបាច់នៃការដំឡើងប្រាក់ឈ្នួលយ៉ាងច្រើន ដែលអាចឱ្យកម្មកររោងចក្រកាត់ដេរកម្ពុជាបំពេញតម្រូវការមូលដ្ឋាន និងរួចផុតពីបំណុល។




កម្មការនីញាំបាយស្រូបពេលព្រឹកមុនចូលធ្វើការ

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

លទ្ធផលរកឃើញពីការសិក្សាអង្កេតដែលត្រូវបានលើកមកពិភាក្សាក្នុងរបាយការណ៍នេះ បង្ហាញពីនិន្នាការគួរឱ្យព្រួយបារម្ភនៃស្ថានភាពត្រដាបត្រដួសកាន់តែខ្លាំង របស់កម្មកររោងចក្រកាត់ដេរកម្ពុជា ដែលចំណូល និងអំណាចទិញរបស់ពួកគេថយចុះ ហើយពួកគេត្រូវរ៉ាប់រងបន្ទុកបំណុលដ៏ធំ។ ខណៈដែលសំណាកក្នុងការសិក្សាអង្កេតនេះ អាចមិនតំណាងឱ្យស្ថិតិឧស្សាហកម្មកាត់ដេរកម្ពុជាទាំងមូល និងមិនទាន់មានការប្រៀបធៀបក្នុងរយៈពេលកំណត់ដែលមានរយៈពេលជាច្រើនឆ្នាំ ដោយប្រើសំណាកដដែល ការសិក្សាអង្កេតទាំងនេះបានលើកឡើងពីលទ្ធផលប្រហាក់ប្រហែលគ្នា ដែលបញ្ជាក់ពីការវិវត្តដូចគ្នា។ ការសិក្សាអង្កេតទាំងអស់សុទ្ធតែផ្តោតលើទិដ្ឋភាពផ្សេងៗនៃបញ្ហានេះ ដូច្នេះ គេអាចប្រើប្រាស់លទ្ធផលដែលទទួលបាន ដើម្បីបំពេញបន្ថែមលើនិន្នាការជារួម។

## និន្នាការទី ១

និន្នាការទីមួយដែលបង្ហាញឡើងដោយរបាយការណ៍ទាំងនេះ គឺប្រាក់ខែបើកបានសរុបរបស់កម្មករកាត់ដេរ មានការថយចុះ។ ការសិក្សាអង្កេតរបស់ CNV បង្ហាញថា មានភាពខុសគ្នាតិចតួចបំផុតរវាងប្រាក់ឈ្នួលគោលក្នុងឧស្សាហកម្មកាត់ដេរ ដោយលើកឡើងថា កម្មករស្ទើរតែទាំងអស់ទទួលបានប្រាក់ឈ្នួលអប្បបរមាមិនលើស ២០០ ដុល្លារ ជាប្រាក់ឈ្នួលគោល។ ចំណុចនេះត្រូវបានបញ្ជាក់ដោយការសិក្សាអង្កេតរបស់សហជីពឯករាជ្យ ដែលលើកឡើងថា កម្មករ ៧៥,៥% ទទួលបានប្រាក់ឈ្នួលអប្បបរមា ២០០ ដុល្លារ ជាប្រាក់ឈ្នួលគោល ធៀបនឹងកម្មករ ៥១% ដែលបានលើកឡើងដូច្នេះកាលពីមុនវិបត្តិកូវីដ-១៩។ មានន័យថា តាមពិតប្រាក់ឈ្នួលគោលថយចុះ ទោះបីជាមានការដំឡើងប្រាក់ឈ្នួលអប្បបរមាកំណត់ដោយច្បាប់ក៏ដោយ។ ក្រៅពីនេះ ការរកចំណូលបន្ថែមពីការងារថែមម៉ោង និងអត្ថប្រយោជន៍ផ្សេងទៀត ដូចជា ប្រាក់ដេរគិតបុង និងប្រាក់បន្ថែមលើវត្តមាន ដែលរួមចំណែកមួយភាគធំដល់ចំណូលជាក់ស្តែង ក៏ថយចុះផងដែរ។ ការសិក្សាអង្កេតដោយសហជីពឯករាជ្យ លើកឡើងថា ចំណូលប្រចាំខែជាមធ្យមពីការងារថែមម៉ោង ថយ ២២ ដុល្លារ (ថយពី ៣៤ ដុល្លារ មកត្រឹម ១១ ដុល្លារ) ក្នុងមួយខែ គិតចាប់ពីឆ្នាំ ២០២០ មក។ ទន្ទឹមនឹងនេះ ការសិក្សាអង្កេតឆ្នាំ ២០២៣ របស់ CNV លើកឡើងពីមធ្យមភាគចំណូល ២៥៧ ដុល្លារ ដែលធៀបនឹងមធ្យមភាគចំណូល ២៧១ ដុល្លារ ដែលបានរាយការណ៍នៅឆ្នាំ ២០២២ គឺតិចជាង ចំនួន ១៤ ដុល្លារ។ ការសិក្សាអង្កេតរបស់ AFWA លើកឡើងពីកម្រិតចំណូលប្រចាំខែប្រហាក់ប្រហែលគ្នា ដែលជាមធ្យមគឺប្រមាណ

២៥៤ ដុល្លារក្នុងមនុស្សម្នាក់ និង ៣៧៨ ដុល្លារក្នុងមួយគ្រួសារ។ ដោយសារការធ្វើឱ្យមានភាពស្មុគស្មាញសម្រាប់ការបែងចែកប្រាក់ឈ្នួលទៅជាប្រាក់ឈ្នួលគោល ក៏ដូចជាអត្ថប្រយោជន៍ផ្សេងៗ ប្រាក់ឧបត្ថម្ភ និងប្រាក់បន្ថែម កម្មកររោងចក្រកាត់ដេរកម្ពុជាបានប្រឈមនឹងការថយចុះប្រាក់ឈ្នួលដោយមិនដឹងខ្លួន ទោះបីជាមានការដំឡើងប្រាក់ឈ្នួលអប្បបរមាក្នុងវិស័យនេះក៏ដោយ។

## និន្នាការទី ២

និន្នាការទី ២ ដែលបង្ហាញឡើងដោយការសិក្សាអង្កេតទាំងនេះ គឺចំណាយក្នុងការរស់នៅរបស់កម្មកររោងចក្រកាត់ដេរកម្ពុជា មានការកើនឡើង ហើយចំណាយទាំងនោះគឺខ្ពស់ជាងកម្រិតចំណូលជាក់ស្តែង។ ការសិក្សាអង្កេតដោយ CNV និង AFWA លើកឡើងពីកម្រិតចំណាយប្រចាំខែប្រហាក់ប្រហែលគ្នា ដោយ CNV លើកឡើងថា ចំណាយប្រចាំខែគឺ ៤២៥ ដុល្លារ ចំណែក AFWA លើកឡើងថា ចំណាយប្រចាំខែ គឺ ៤២៤ ដុល្លារ។ កម្រិតចំណាយនេះខ្ពស់ជាងចំណូលប្រចាំខែជាមធ្យមរបស់គ្រួសារ ដែល AFWA លើកឡើងថា មានចំនួន ៣៧៨ ដុល្លារ។ ម្យ៉ាងវិញទៀត នេះជាការកើនឡើងយ៉ាងច្រើនពីចំណាយជាមធ្យមចំនួន ៣៤៥ ដុល្លារក្នុងមួយខែ ដែលរាយការណ៍ដោយ CNV ក្នុងឆ្នាំ ២០២២។ មានន័យថា កម្រិតថ្លៃសម្រាប់សម្ភារៈប្រើប្រាស់ចាំបាច់ កើនឡើងក្នុងអត្រាខ្ពស់ខ្លាំងជាងអត្រាអតិផរណាផ្លូវការ ៥,៣%។ ដូច្នេះវាជារឿងធម្មតាដែល CNV រាយការណ៍ថា កម្មករ ៤០% មានការងារមួយផ្សេងទៀត (ក្រៅពីការងារ ៤៨ ម៉ោងក្នុងមួយសប្តាហ៍ និងការងារបន្ថែមម៉ោង) ដើម្បីបង្គ្រប់ការចាយវាយ។ ក្រៅពីនេះការសិក្សាអង្កេតបង្ហាញថា កម្មករកាត់ដេរកំពុងកាត់បន្ថយចំណាយថ្លៃម្ហូបអាហារ និងមិនមានលទ្ធភាពសន្សំប្រាក់សម្រាប់គ្រាអាសន្ន។

## និន្នាការទី ៣

និន្នាការទី ៣ ដែលបង្ហាញឡើងដោយការសិក្សាអង្កេតទាំងនេះគឺ កម្មកររោងចក្រកាត់ដេរកម្ពុជាភាគច្រើនលើសលប់ ជាប់ជុំពាក់ក្នុងអន្ទាក់បំណុល។ ការសិក្សាអង្កេតរបស់ CNV លើកឡើងថា កម្មករ ៧៧% ជំពាក់បំណុល ដែលបំណុលជាមធ្យមគឺ ៥.000 ដុល្លារ។ ការសិក្សាអង្កេតរបស់សហជីពឯករាជ្យ លើកឡើងថា កម្មករ ៩១% ជំពាក់បំណុល ដោយកម្មករ ៥៤% មិនមានលទ្ធភាពសងបំណុល និងកម្មករ ៣៤% ខ្ចីប្រាក់ពីប្រភពជាច្រើន។ ការសិក្សាអង្កេត

នេះលើកឡើងទៀតថា កម្មករ ៧០% មានបន្ទុកបំណុលកាន់តែច្រើនតាំងពីវិបត្តិកូវីដ-១៩ ជាពេលដែលពួកគេត្រូវបង្ខំចិត្តខ្ចីប្រាក់គេដើម្បីចិញ្ចឹមជីវិត។

ដូច្នេះ ការសិក្សាអង្កេតទាំងនេះបង្ហាញថា ជាទូទៅ ចំណូលរបស់កម្មកររោងចក្រកាត់ដេរកម្ពុជា ថយចុះ ខណៈដែលចំណាយក្នុងការរស់នៅ និងបំណុល កើនឡើង។ ទោះជាមានការដំឡើងប្រាក់ឈ្នួលអប្បបរមាបន្តិចបន្តួចក្នុងរយៈពេលពីរបីឆ្នាំចុងក្រោយនេះក៏ដោយ ប៉ុន្តែកម្មកររោងចក្រកាត់ដេរកម្ពុជានៅតែមានជីវភាពខ្វះខាត។ ដូច្នេះ កម្មកររោងចក្រកាត់ដេរកម្ពុជាពិតជាត្រូវការការដំឡើងប្រាក់ឈ្នួលច្រើនដើម្បីរ៉ាប់រងចំណាយក្នុងការរស់នៅ និងសងបំណុល។ លើសពីនេះ ការដំឡើងប្រាក់ឈ្នួលអប្បបរមា ត្រូវប៉ះប៉ូវការបាត់បង់ចំណូលបន្ថែមពីការងារថែមម៉ោង ប្រាក់បន្ថែម និងអត្ថប្រយោជន៍នានា ដើម្បីធានាថា ប្រាក់ខែបើកបានសរុប ពិតជាកើនឡើងប្រាកដមែន។ របាយការណ៍របស់ CNV ស្នើឱ្យមានការដំឡើងប្រាក់ឈ្នួលអប្បបរមាពី ៣០០ ដុល្លារ ដល់ ៥០០ ដុល្លារ ដើម្បីបំពេញតម្រូវការមូលដ្ឋានរបស់កម្មករ ខណៈដែល AFWA ស្នើឱ្យដំឡើងប្រាក់ឈ្នួលសមរម្យដល់ ៧០១ ដុល្លារសម្រាប់ប្រទេសកម្ពុជា។ ក្នុងករណីណាក៏ដោយ ចាំបាច់ត្រូវមានការដំឡើងប្រាក់ឈ្នួលអប្បបរមាយ៉ាងច្រើន ដើម្បីឈានទៅរកប្រាក់ឈ្នួលសមរម្យនៅក្នុងឧស្សាហកម្មកាត់ដេរ នៅកម្ពុជា។

# ឯកសារយោង

Asian Floor Wage Alliance. (2022). Towards a woman-centred living wage beyond borders.

Asian Floor Wage Alliance. (2022). Cambodia living wage figure.

CNV Internationaal. (2023). Making the case for higher wages in the Cambodian garment sector.

CENTRAL. (2023). Union survey.